ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០៦៥.....សហវ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១៤

សេចក្តីជូនដំណឹង

ស្តីពី

ការកែសម្រួលមូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក

យោងតាមប្រការ ២ នៃប្រកាសលេខ ៥២១ សហវ.ប្រក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការសម្រេចដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ លើលិខិតលេខ ៤៥៣៩ សហវ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តឲ្យមានភាពទន់ភ្លន់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំការអនុវត្តមូលដ្ឋានគិតអាករពិសេសសម្រាប់ឆ្នាំ២០១៤ និង២០១៥ ដូចខាងក្រោម÷

មូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុកត្រូវបានកំណត់ស្មើនឹង ៩០ ភាគរយ នៃថ្លៃផ្គត់ផ្គង់កត់ត្រាក្នុងវិក្កយបត្រឲ្យទៅអតិថិជន ដោយមិនរួមបញ្ចូល÷

- អាករលើតម្លៃបន្ថែម និងអាករពិសេសខ្លួនឯង សម្រាប់អ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាស (របបពិត)
- អាករលើផលរបរ និងអាករពិសេសខ្លួនឯង សម្រាប់អ្នកជាប់ពន្ធក្នុងរបបម៉ៅការ។

មូលដ្ឋានគិតអាករពិសេសថ្មីនេះនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ នេះតទៅ។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីជានាយកសហគ្រាសផលិតទំនិញជាប់អាករពិសេសក្នុងស្រុកទាំងអស់មេត្តាជ្រាប និងអនុវត្តឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាពខ្ពស់។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ចរណិត. អូន ព័ន្ធមុនីរ័ត្ន

ផ្លូវលេខ ៤២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
#42 Sangkat Wat Phnom Khan Daun Penh Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798